# សេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងការពារបរិស្ថានស្តីពីការចេញគោលការណ៍ណែនាំសម្រាប់ការការពារបរិស្ថានក្នុងកិច្ចសហប្រតិបត្តិការ និងវិនិយោគបរទេស

ចេញផ្សាយដោយៈ ក្រសួងពាណិជ្ជកម្ម និងក្រសួងការពារបរិស្ថាននៃសាធារណរដ្ឋប្រជាមា-និតចិន

សាង ហេ ហាន [២០១៣] លេខ៧៤

កាលបរិច្ឆេទចេញផ្សាយៈ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣

ជូនចំពោះមន្ទីរពាណិជ្ជកម្មមានសមត្ថកិច្ច និងមន្ទីរការពារបរិស្ថានគ្រប់ខេត្ត គ្រប់តំបន់ស្វយ័ត សាលាក្រុងទាំងអស់ ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលកណ្តាល បណ្តាក្រុងដែលចុះបញ្ជីដាច់ដោយឡែកនៅក្នុងផែនការរដ្ឋ និងក្រុមហ៊ុនផលិតកម្ម និងសំណង់ស៊ីនជាំង និងសហគ្រាសកណ្តាលទាំងអស់។

ដើម្បីតម្រង់ទិសដល់សហគ្រាសទាំងអស់នៅក្នុងប្រទេសចិន ឲ្យគ្រប់គ្រងតាមគោលការណ៍ច្បាប់បន្ថែមទៀតលើកិច្ចការពារបរិស្ថានរបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការ និងការវិនិយោគបរទេសដើម្បីណែនាំសហគ្រាសទាំងនេះ ឲ្យមានការទទួលខុសត្រូវក្នុងការការពារបរិស្ថាននៅក្នុងសង្គមរបស់ខ្លួន និងដើម្បីជំរុញឲ្យមានការអភិវឌ្ឍ កិច្ចសហប្រតិបត្តិការ និងការវិនិយោគបរទេសប្រកបដោយនិរន្តរភាព ដូច្នេះយើងបានបង្កើត និងប្រកាសឲ្យប្រើប្រាស់*គោលការណ៍ណែនាំស្តីពីកិច្ចការពារបរិស្ថានក្នុងកិច្ចសហប្រតិបត្តិការ និងវិនិយោគបរទេស* (ដែលចាប់ពេលនេះទៅហៅថា គោលការណ៍ណែនាំទាំងនេះ)។

មន្ទីរបរិស្ថានមានសមត្ថកិច្ច និងមន្ទីរការពារបរិស្ថាននៅគ្រប់តំបន់ត្រូវបង្កើនការផ្សព្វផ្សាយគោលការណ៍ណែនាំទាំងនេះជាសាធារណៈ និងណែនាំដល់សហគ្រាសទាំងអស់នៅក្នុង

ប្រទេសចិនឲ្យបង្កើនការយល់ដឹងអំពីកិច្ចការពារបរិស្ថាន ត្រូវស្វែងយល់និងឃ្លាំមើលគោលនយោបាយការពារបរិស្ថាន និងបទបញ្ញត្តិរបស់ប្រទេសសាមីពាក់ព័ន្ធការវិនិយោគ និងកិច្ចសហប្រតិបត្តិការក្រៅប្រទេសដើម្បីស្វែងយល់អំពីផលប្រយោជន៍ទៅវិញទៅមក។

**ក្រសួងពាណិជ្ជកម្ម និងក្រសួងការពារបរិស្ថាននៃសាធារណរដ្ឋប្រជាមានិតចិន**

**ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣**

## គោលការណ៍ណែនាំស្តីពីកិច្ចការពារបរិស្ថានក្នុងកិច្ចសហប្រតិបត្តិការ និងវិនិយោគបរទេស

មាត្រា១៖ គោលការណ៍ណែនាំទាំងនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីណែនាំសហគ្រាសទាំងអស់នៅក្នុងប្រទេសចិន ឲ្យគ្រប់គ្រងតាមគោលការណ៍ច្បាប់បន្ថែមទៀតស្តីពីការការពារបរិស្ថានក្នុងកិច្ចសហប្រតិបត្តិ និងវិនិយោគបរទេស កំណត់ និងទប់ស្កាត់ហានិភ័យបរិស្ថានឲ្យបានទាន់ពេលវេលា ណែនាំសហគ្រាសទាំងអស់ឲ្យចេះទទួលខុសត្រូវចំពោះកិច្ចការពារបរិស្ថាននៅក្នុងសង្គមរបស់ខ្លួន បង្ហាញស្ថានភាពអន្តរជាតិល្អៗដល់សហគ្រាសចិន និងគាំទ្រដល់ការអភិវឌ្ឍរបស់ប្រទេសសាមីប្រកបដោយនិរន្តរភាព។

មាត្រា២៖ *គោលការណ៍* នេះ អនុវត្តចំពោះការការពារបរិស្ថានដោយសហគ្រាសចិនទាំងអស់ក្នុងសកម្មភាពសហប្រតិបត្តិការ និងវិនិយោគបរទេស ដែលសហគ្រាសទាំងអស់នោះត្រូវតែគោរពប្រកបដោយមនសិការខ្ពស់។

មាត្រា៣៖ តាមគោលការណ៍ណែនាំនេះ បញ្ជាក់ថា ក្នុងដំណើរការនៃការបំពេញតួនាទីយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវក្នុងការការពារបរិស្ថានសហគ្រាសទាំងអស់ត្រូវគោរពដល់ជំនឿសាសនា ប្រពៃណីវប្បធម៌ និង

ទំនៀមទម្លាប់របស់ប្រជាជនរស់នៅក្នុងសហគមន៍ ដែលជាម្ចាស់ប្រទេស សិទ្ធិស្របច្បាប់ស្តីពីការការពារសុវត្ថិភាព និងផលប្រយោជន៍របស់កម្មករ បើកវគ្គបណ្តុះបណ្តាល ផ្តល់ឱកាសការងារដល់ប្រជាជនរស់នៅក្នុងតំបន់ជុំវិញ លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន បរិស្ថាននិងសហគមន៍ ដោយភាពសុខដុមរមនា និងធ្វើកិច្ចសហប្រតិបត្តិការដើម្បីផលប្រយោជន៍ទៅវិញទៅមក។

មាត្រា៤៖ ដោយប្រកាន់ខ្ជាប់ទៅនឹងទស្សនទាននៃការអភិរក្សធនធាន និងបរិស្ថាន ដូច្នេះសហគ្រាសទាំងអស់ត្រូវអភិវឌ្ឍសេដ្ឋកិច្ចបៃតងនិងកាត់បន្ថយកាបូន ហើយអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដើម្បីស្វែងយល់ពីស្ថានភាព "ឈ្នះ ឈ្នះ" ស្តីពីការការពារបរិស្ថាននិងផលប្រយោជន៍ផ្ទាល់ខ្លួនរួម។

មាត្រា៥៖ សហគ្រាសទាំងអស់ត្រូវស្វែងយល់ និងពិនិត្យលើមាត្រា និងបទប្បញ្ញត្តិនៃច្បាប់របស់ម្ចាស់ប្រទេសទាក់ទងនឹងការការពារបរិស្ថាន។

ចំពោះគម្រោងដែលវិនិយោគលើការសាងសង់ ហើយប្រតិបត្តិការដោយសហគ្រាសទាំងនោះ គឺត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានទាក់ទងទៅនឹងគោលការណ៍ការការពារបរិស្ថានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ម្ចាស់ប្រទេស។

មាត្រា៦៖ សហគ្រាសទាំងអស់ត្រូវបញ្ចូលគោលការណ៍ ស្តីពីការការពារបរិស្ថានទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគ្រាសរបស់ខ្លួន ក៏ដូចជាទៅក្នុងផែនការផលិតកម្ម និងប្រតិបត្តិការដែរ។ ត្រូវបង្កើតច្បាប់ និងបទប្បញ្ញត្តិសម្រាប់

ការការពារបរិស្ថាន និងពង្រឹងការគ្រប់គ្រងបរិស្ថាន សុខភាព និងសុវត្ថិភាពផលិតកម្មរបស់សហគ្រាស។ លើសពីនេះទៀត សហគ្រាសទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់សេវាកម្មបរិស្ថានរួមគ្នា។

**មាត្រា៧៖** សហគ្រាសទាំងអស់ត្រូវបង្កើតប្រព័ន្ធបណ្តុះបណ្តាលសមស្រប ស្តីពីការការពារបរិស្ថានដើម្បីផ្តល់ការអប់រំដល់បុគ្គលិកឲ្យបានសមរម្យ និងការបណ្តុះបណ្តាលទាក់ទងនឹងបរិស្ថាន សុខភាព និងសុវត្ថិភាពផលិតកម្ម ដើម្បីឲ្យពួកគាត់អាចយល់ដឹងបានច្បាស់អំពីច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិរបស់ម្ចាស់ប្រទេសទាក់ទងនឹងការការពារបរិស្ថាន និងការគ្រប់គ្រងការបញ្ចេញសារធាតុដែលមានគ្រោះថ្នាក់ ការទប់ស្កាត់គ្រោះថ្នាក់បណ្តាលមកពីបរិស្ថាន និងការយល់ដឹងផ្សេងៗទៀតពាក់ព័ន្ធបរិស្ថាន ដើម្បីបង្កើនការយល់ដឹងរបស់បុគ្គលិកអំពីការតព្វកិច្ចតាមច្បាប់ និងគុណភាពនៃការការពារបរិស្ថាន។

**មាត្រា៨៖** អនុលោមតាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិរបស់ម្ចាស់ប្រទេស សហគ្រាសទាំងអស់ត្រូវអនុវត្តដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន លើគម្រោងអភិវឌ្ឍន៍ និងដំណើរការសាងសង់ ក៏ដូចជាលើសកម្មភាពផលិតកម្ម និងប្រតិបត្តិការដែរ។ ត្រូវចាត់វិធានការសមស្របដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចកើតឡើង ដោយផ្អែកលើលទ្ធផលដែលបានមកពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ។

**មាត្រា៩៖** សហគ្រាសទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យគិតពិចារណាពេញលេញអំពីផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ និងដំណើរការសាងសង់

និងសកម្មភាពផលិតកម្ម និងប្រតិបត្តិការ ដែលអាចប៉ះពាល់លើបរិស្ថានសង្គម ដូចជាមរតកប្រវត្តិសាស្ត្រ និងវប្បធម៌ តំបន់បោះជុំរំ និងប្រពៃណីសម័យបុរាណ និងចាត់វិធានការសមស្របដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចកើតមាន។

មាត្រា១០៖ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌច្បាប់ បទប្បញ្ញត្តិ និងបទដ្ឋានរបស់ម្ចាស់ប្រទេសពាក់ព័ន្ធនឹងការការពារបរិស្ថាននោះ សហគ្រាសទាំងអស់ត្រូវសាងសង់និងដំណើរការដំឡើងប្រព័ន្ធការពារការបំពុលបរិស្ថាន អនុវត្តវិធានការទប់ស្កាត់ការបំពុលបរិស្ថាន និងធ្វើឲ្យប្រាកដថា ការបំភាយឧស្ម័នកាកសំណល់វត្ថុរាវ កាកសំណល់វត្ថុរឹង ឬការបំពុលបរិស្ថានដទៃទៀតត្រឹមត្រូវតាមបទដ្ឋានច្បាប់របស់ម្ចាស់ប្រទេស ។

មាត្រា១១៖ មុនពេលចាប់ផ្តើមដំណើរការគម្រោងសាងសង់ សហគ្រាសទាំងអស់ត្រូវបានជំរុញលើកទឹកចិត្តឲ្យពិនិត្យ និងវាយតម្លៃលើបរិស្ថាន សម្រាប់ការដ្ឋានសាងសង់ដែលបានស្នើឡើងនោះ។ ត្រូវស្វែងយល់អំពីស្ថានភាព និងប្រវត្តិទីតាំងរបស់គម្រោងនិងតំបន់ជុំវិញ និងបញ្ចូលលទ្ធផលនៃការពិនិត្យនិងវាយតម្លៃបរិស្ថាននោះទៅក្នុងរបាយការណ៍។

សហគ្រាសទាំងអស់ត្រូវបានជំរុញ និងលើកទឹកចិត្ត ឲ្យឃ្លាំមើលការបញ្ចេញសារធាតុបំពុលបរិស្ថាន និងយល់ដឹងជាប្រចាំអំពីស្ថានភាពបំពុលបរិស្ថាន នៃសហគ្រាសទាំងអស់ និងបញ្ចូលលទ្ធផលនៃការឃ្លាំមើលនោះទៅក្នុងរបាយការណ៍។

មាត្រា១២៖ សហគ្រាសទាំងអស់ត្រូវបានគាំទ្រ ឲ្យអនុវត្តវិធានការការពារបរិស្ថានឲ្យបានហ្មត់ចត់ចំពោះសហគ្រាសគោលដៅ មុនពេលទទួលសហគ្រាសនៅក្រៅប្រទេស ដែលផ្តោតលើការវាយតម្លៃលើកាកសំណល់គ្រោះថ្នាក់ដែលបានកើតឡើងពីបណ្តាសកម្មភាពប្រតិបត្តិការជាប្រវត្តិសាស្ត្ររបស់ខ្លួន និងការបំពុលបរិស្ថានដី និងក្នុងដីក៏ដូចជាបំណុលបរិស្ថានរបស់សហគ្រាសគោលដៅពាក់ព័ន្ធកន្លែងនោះ។ លើកទឹកចិត្តនិងជំរុញសហគ្រាសទាំងអស់ឲ្យអនុវត្តវិធានការការពារបរិស្ថាន ក្នុងគោលបំណងកាត់បន្ថយលទ្ធភាពនៃហានិភ័យបរិស្ថាន។

មាត្រា១៣៖ សហគ្រាសទាំងអស់ត្រូវបង្កើតផែនការគ្រប់គ្រងកាកសំណល់ ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដែលអាចកកើតឡើង ក្នុងពេលដំណើរការផលិតកម្ម។ ខ្លឹមសារនៃផែនការទាំងនេះត្រូវបញ្ចូលវិធានការកាត់បន្ថយចំនួននិងគ្រោះថ្នាក់ដោយសារកាកសំណល់ទាំងនេះ ក៏ដូចជាវិធានការក្នុងការរក្សាទុក ដឹកជញ្ជូន ប្រើប្រាស់ និងការបញ្ចេញចោលកាកសំណល់ដែលមានគ្រោះថ្នាក់ទាំងនេះ។

មាត្រា១៤៖ ចំពោះហានិភ័យដែលអាចកើតមានពាក់ព័ន្ធគ្រោះថ្នាក់ដោយសារបរិស្ថាន សហគ្រាសទាំងអស់ត្រូវបង្កើតផែនការយថាហេតុសម្រាប់បង្ការគ្រោះថ្នាក់ដោយសារបរិស្ថាននៅពេលអនាគត និងស្ថានភាពគ្រាអាសន្នដទៃទៀតបណ្តាលមកពីធម្មជាតិ បញ្ហាផ្សេងៗ និងគ្រោះថ្នាក់ដោយសារបរិស្ថានដែលអាចកើតមាន និងបង្កើតប្រព័ន្ធរាយការណ៍និងទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន អាជ្ញាធរគ្រប់គ្រងកិច្ចការពារបរិស្ថាន សាធារណជន

ដែលអាចប្រឈមផលប៉ះពាល់ និងជាមួយទីស្នាក់ការរបស់សហគ្រាសចិនផ្សេងៗទៀត។

ផែនការយថាហេតុនោះ ត្រូវមានប្រព័ន្ធរៀបចំ និងទទួលខុសត្រូវផ្នែកការងារគ្រប់គ្រងគ្រាអាសន្ន និងយន្តការទប់ស្កាត់ និងប្រកាសអាសន្ន នីតិវិធីដោះស្រាយ ការធានាស្ថានភាពគ្រាអាសន្ន និងការស្តារ និងការកសាងឡើងវិញ បន្ទាប់ពីគ្រាអាសន្ន។ លើកទឹកចិត្តសហគ្រាសទាំងអស់ឲ្យរៀបចំការហ្វឹកហាត់ទប់ទល់គ្រាអាសន្ន និងធ្វើការកែតម្រូវឲ្យបានទាន់ពេលវេលាចំពោះផែនការទាំងនោះ ក៏ដូចជាចាត់វិធានការ ដូចជា ការធានារ៉ាប់រងការទទួលខុសត្រូវការបំពុលបរិស្ថាន ដើម្បីបញ្ចៀសហានិភ័យនៃគ្រោះថ្នាក់ បរិស្ថាន។

មាត្រា១៥៖ សហគ្រាសទាំងអស់ត្រូវពិចារណារដោយប្រុងប្រយ័ត្នអំពីទិសដៅមុខងារអេកូឡូហ្ស៊ីនៃតំបន់របស់គម្រោង ហើយសហគ្រាសទាំងនេះ ដោយមានការសម្របសម្រួលពីរដ្ឋាភិបាលនៃម្ចាស់ប្រទេស និងរបស់សហគមន៍មូលដ្ឋានអាចមានអាទិភាពក្នុងការចាត់វិធានការបែបនេះនៅនឹងកន្លែង និងនៅក្បែរតំបន់អភិរក្សធនធានសត្វ និងរុក្ខជាតិដែលសមនឹងអភិរក្ស និងដែលអាចប្រឈមផលប៉ះពាល់ ដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរទៅលើជីវចម្រុះក្នុងមូលដ្ឋាន។ ចំពោះផលប៉ះពាល់លើអេកូឡូហ្ស៊ី ដែលបង្កឡើងដោយសកម្មភាពវិនិយោគ សហគ្រាសទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យស្តារបរិស្ថានអេកូឡូហ្ស៊ីឡើងវិញ ដោយអនុលោមតាមលក្ខខណ្ឌច្បាប់ និងរបស់ម្ចាស់ប្រទេស ឬវិធានអនុវត្តទូទៅក្នុងឧស្សាហកម្មនេះ។

មាត្រា១៦៖ លើកទឹកចិត្ត និងជំរុញសហគ្រាសទាំងអស់ឲ្យធ្វើផលិតកម្មស្អាតស្អំ ជំរុញឲ្យមានការកែច្នៃរបស់សម្រាប់ប្រើប្រាស់ឡើងវិញ កាត់បន្ថយការបំពុលបរិស្ថានពីប្រភពនានា លើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពនិងកាត់បន្ថយការកកើត និងការបំភាយឧស្ម័នដែលបំពុលបរិស្ថានក្នុងដំណើរការផលិតកម្ម សេវាកម្ម និងក្នុងការប្រើប្រាស់ផលិតផលជាដើម។

មាត្រា១៧៖ លើកទឹកចិត្តសហគ្រាសទាំងអស់ឲ្យអនុវត្តលទ្ធកម្មបៃតង និងផ្តល់ការអនុគ្រោះចំពោះផលិតផលដែលបានមកពីបរិស្ថាននោះ។

សហគ្រាសទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យសុំលិខិតបញ្ជាក់ ស្តីពីប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងលិខិតបញ្ជាក់ស្តីពីការដាក់ស្លាកសញ្ញាសម្គាល់ពាក់ព័ន្ធបរិស្ថានសម្រាប់ផលិតផលពាក់ព័ន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ម្ចាស់ប្រទេស។

មាត្រា១៨៖ លើកទឹកចិត្តសហគ្រាសទាំងអស់ឲ្យផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធបរិស្ថានជាប្រចាំ និងផ្សព្វផ្សាយផែនការរបស់ខ្លួនស្តីពីការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីការការពារបរិស្ថាន វិធានការអនុវត្ត និងស្នាដៃនៃការបំពេញការងារបរិស្ថានដែលសម្រេចបាន។ល។

មាត្រា១៩៖ សហគ្រាសទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យពង្រឹងទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋាភិបាល និងអាជ្ញាធរទទួលបន្ទុកការពារបរិស្ថានរបស់ម្ចាស់ប្រទេស ព្រមទាំងលើកទឹកចិត្តឲ្យស្វែងរកមតិ និងសំណើស្តីពីបញ្ហាការពារបរិស្ថាន។

មាត្រា២០៖ គាំទ្រសហគ្រាសទាំងអស់ឲ្យបង្កើតមធ្យោបាយសម្រាប់ទាក់ទង និងបង្កើតយន្តការពិភាក្សាសម្រាប់ការទទួលខុសត្រូវបរិស្ថានសង្គម របស់សហគ្រាសទាំងអស់។ គាំទ្រការផ្តួចផ្តើមគំនិតពង្រឹងទំនាក់ទំនងជាមួយសហគមន៍របស់ខ្លួននិងក្រុមផ្សេងៗទៀតនៅក្នុងសង្គម និងទទួលយកមតិ និងសំណើនានាទាក់ទង នឹងផលប៉ះពាល់បរិស្ថានដោយសារគម្រោងសាងសង់ និងសកម្មភាពប្រតិបត្តិការរបស់ខ្លួនតាមរយៈវេទិកានិងសវនាការនានាទៅតាមលក្ខខណ្ឌច្បាប់ និងបទប្បញ្ញត្តិច្បាប់របស់ម្ចាស់ប្រទេស។

មាត្រា២១៖ សហគ្រាសទាំងអស់ត្រូវបានលើកទឹកចិត្តចូលរួមយ៉ាងសកម្ម និងគាំទ្រសកម្មភាពដែលផ្តល់ផលប្រយោជន៍ជាសាធារណៈនៅតាមមូលដ្ឋាន ដើម្បីកិច្ចការពារបរិស្ថាន ផ្សព្វផ្សាយទស្សនទានស្តីពីកិច្ចការពារបរិស្ថាន និងកសាងមុខមាត់ល្អរបស់សហគ្រាស ទាក់ទងទៅនឹងការការពារបរិស្ថាន។

មាត្រា២២៖ លើកទឹកចិត្តដល់សហគ្រាសទាំងអស់ឲ្យធ្វើការស្រាវជ្រាវ និងសិក្សាអំពីគោលការណ៍ បទដ្ឋាននិងវិធីអនុវត្តន៍ទាក់ទងនឹងកិច្ចការពារបរិស្ថានដែលត្រូវបានអនុម័តដោយអង្គការអន្តរជាតិ និងពហុស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត។

ឯកសារបកប្រែភាសាខ្មែរនេះមិនមែនជាការបកប្រែផ្លូវការទេ និងអាចប្រើសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ មានតែភាសាចិនដែលជាឯកសារមូលដ្ឋានត្រឹមត្រូវ។

http://www.mofcom.gov.cn/article/b/bf/201302/20130200039930.shtml